01369632

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 12 / 2016
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E443/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
**Trial Chamber**
**Chambre de Premiere instance**
លេខ: ៧២៨ អ.វ.ត.ក/អ.ជ.ស.ដ

**Declassified to Public**
**05 April 2019**

## ជូនចំពោះ

## លោក ឆាយ វិសុទ្ធ ប្រធានការិយាល័យនៃសារមន្ទីរទួលស្លែង

**កម្មវត្ថុ៖** ការបរិច្ចាគឯកសារពីសាស្ត្រាចារ្យ Walter Heynowski និងការស្នើសុំព័ត៌មាន

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជូនដំណឹងដល់លោកប្រធានថា អង្គជំនុំជម្រះសាលាដំបូងបាន ទាក់ទងជាមួយនឹងជនជាតិអាល្លឺម៉ង់មួយរូប គឺលោកសាស្ត្រាចារ្យ Walter Heynowski ដែលបាន យល់ព្រមបរិច្ចាគនូវឯកសារមួយចំនួនដល់សារៈមន្ទីរទួលស្លែង បន្ទាប់ពីអង្គជំនុំជម្រះប្រើប្រាស់ឯក សារទាំងនេះនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះរួចហើយ។ ឯកសារទាំងនេះរួមមាន (១) សៀវភៅ ពណ៌ទឹកក្រូចដែលចងក្រងកំណត់ត្រាប្រចាំថ្ងៃរបស់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដែលបានមក ពីមន្ទីរសន្តិសុខ ស-២១ ក្នុងឆ្នាំ ១៩៧៩ ឬ ឆ្នាំ ១៩៨០ និង (២) សន្លឹកទំព័រដែលបានដាច់ចេញពី សៀវភៅជាច្រើនសន្លឹកជាភាសាខ្មែរ ដែលត្រូវបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ ក្នុងឆ្នាំ ១៩៧៩ ឬ ឆ្នាំ ១៩៨០ ដែរ ព្រមទាំងការបកប្រែជាភាសាអាល្លឺម៉ង់ដែលសាស្ត្រាចារ្យ Heynowski ទទួលបាន។

អង្គជំនុំជម្រះត្រូវការប្រើប្រាស់សៀវភៅពណ៌ទឹកក្រូច ដែលចងក្រងកំណត់ត្រាប្រចាំថ្ងៃរបស់អ្នកជាប់ ឃុំនៅមន្ទីរសន្តិសុខ ស-២១ នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ រួចនឹង ប្រគល់សៀវភៅនេះ ជូនលោកប្រធានជាការបរិច្ចាគចុងក្រោយនៅពេលវេលាសមស្របខាងមុខ។ ក៏ ប៉ុន្តែ ដោយសន្លឹកទំព័រដែលបានដាច់ចេញពីសៀវភៅមានសភាពមិនល្អទាល់តែសោះ ដែលតម្រូវឱ្យ មានការថែទាំជាបន្ទាន់ដោយបណ្ណារក្សដែលមានវិជ្ជាជីវៈដើម្បីរក្សាទុកឯកសារនេះ។ យើងពុំដឹងច្បាស់

01369633

E443/4

ថា តើការថតទំព័រទាំងនេះជាទម្រង់អេឡិចត្រូនិកអាចធ្វើបានឆាប់រហ័សដែរ ឬ យ៉ាងណានោះទេ។ ហេតុនេះ អង្គជំនុំជម្រះស្នើឱ្យបញ្ជូនឯកសារជាសន្លឹកទំព័រដែលដាច់ចេញពីសៀវភៅទាំងនេះទៅលោកប្រធានជាបន្ទាន់ និងស្នើសុំព័ត៌មានខាងក្រោមពីលោកប្រធាន៖

(១) សេចក្តីបរិយាយលម្អិតនៃឯកសារនីមួយៗ រួមទាំង លក្ខណៈ និងចំណងជើង ចំនួនទំព័រ ភាសាដែលបានប្រើ លក្ខណៈនៃឯកសារ (វាយកុំព្យូទ័រ សរសេរដោយដៃ ចម្រុះ ។ល។) និងសភាពរបស់ឯកសារ។

(២) ការបង្ហាញថា តើអាចថែរក្សា និងថតស្កេន/ថតជារូបភាព ឯកសារទាំងនេះបានដែរ ឬទេ។ ប្រសិនបើអាចធ្វើបាន តើការថតស្កេន ឬ ថតជារូបភាពឯកសារទាំងនេះ ត្រូវចំណាយពេលប៉ុន្មាន ទើបអាចប្រគល់ជូនមកអង្គជំនុំជម្រះសាលាដំបូងបាន។

(៣) ការវាយតម្លៃថា តើឯកសារទាំងនេះជាឯកសារថ្មីដែលមិនទាន់មាននៅក្នុងបណ្ណាសារដ្ឋានរបស់ទួលស្លែង ឬ ក៏ជាឯកសារជាន់គ្នាទៅនឹងឯកសារដែលមានរួចហើយនៅក្នុងបណ្ណាសារដ្ឋាននៅទួលស្លែង ឬ បណ្ណាសារដ្ឋានសាធារណៈផ្សេងទៀត។ និង

(៤) ការវាយតម្លៃ *បឋម* អំពីយថាភាពនៃឯកសារជាភាសាខ្មែរ។

យើងស្នើឱ្យមានការឆ្លើយតបពីលោកប្រធានវិញយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ដោយហេតុថា កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ជិតនឹងបញ្ចប់ហើយ។ យើងខ្ញុំសូមថ្លែងអំណរគុណទុកជាមុនចំពោះការជួយជ្រោមជ្រែងពីសំណាក់លោកប្រធាន។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C * C.E.T.C.

**និល ណុន**